**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**Ministry of Environment**

លេខៈ ៦១០ ប៨ ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១០

## ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "គគីរប្រហោង" ភូមិស្រែវាលលិច និង ភូមិសំព័រតូច ឃុំដងកាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ " គគីរប្រហោង "
- តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន ។

## សំរេច

**ប្រការ ១** : រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "**គគីរប្រហោង**" ដែលស្ថិតនៅក្នុងភូមិស្រែវាលលិចនិងភូមិសំព័រតូច ឃុំដងកាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ នៃដែនជម្រកសត្វព្រៃបឹងពែរ ។

**ប្រការ ២** : សហគមន៍តំបន់ការពារធម្មជាតិ **"តតីរប្រហោង"** ក្នុងដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីទំហំ **១៩២៤ហិចតា** បានកំណត់ទីតាំងព្រំប្រទល់ក្នុងផែនទីដែលមានអាប់ស៊ីស និងកូអ័រដោនេ ដូចខាងក្រោម :

| ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y | ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y |
|---|---|---|---|---|---|
| A | 527520 | 1459852 | E | 525006 | 1464521 |
| B | 525712 | 1457634 | F | 526069 | 1465152 |
| C | 525032 | 1457900 | J | 527828 | 1465783 |
| D | 525016 | 1458868 | H | 526932 | 1464405 |

**ប្រការ ៣** : ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ **"តតីរប្រហោង"** នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ ៤** : អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានពាក់ព័ន្ធ កម្រងតំបន់ការពារធម្មជាតិស្ទឹងសែន មន្ទីរបរិស្ថានខេត្តកំពង់ធំ ដែនជម្រកសត្វព្រៃបឹងពែរ និងសហគមន៍តំបន់ការពារធម្មជាតិ " **តតីរប្រហោង** " នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក_ម៉ារ៉េត**

បណ្ឌិត.ជីវវិទ្យា

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សាលាខេត្តកំពង់ធំ
- ឯកសារ-កាលប្បវត្តិ